ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ៖ ...២៣២.... "ក១"

ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៧៧៩

ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២

សំណុំរឿងស៊ើបសួរលេខ៖ ២០០៩

ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ៖ ៤២១៤

ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក នៅសាលសវនាការទី៥ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៧៧៩ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] **គឿន** ភេទស្រី អាយុ៤៩ឆ្នាំ (កើតថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៣) មានទីលំនៅកំណើតនៅភូមិ [redacted] ខេត្តស្វាយរៀង បច្ចុប្បន្ននៅផ្ទះលេខ៩៩ ផ្លូវលំ ភូមិត្រពាំងមាន សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្តីឈ្មោះ [redacted] សាវ៉េត មានកូនចំនួន០៣នាក់ ឪពុកឈ្មោះ [redacted] ណែន (ស) ម្តាយឈ្មោះ [redacted] អេង (ស) ជាទីតិជន ទោសពីមុនៈគ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅផ្ទះលេខ៩៩ ផ្លូវលំ ភូមិត្រពាំងមាន សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធឱ្យជនជាប់ចោទឈ្មោះ [redacted] **គឿន**។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គញ្ញាវី** ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីកន្លែងកំណើតភូមិព្រៃ ស្រុកបាទី ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខH049 ផ្លូវលេខ១៣០D2 បុរីម៉ូនែឡូ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរជាគិលានុបដ្ឋាយិកានៅមន្ទីរពេទ្យកាល់ម៉ែត្រ ឪពុកឈ្មោះ [redacted] **ផល្លា** (រ) ម្តាយឈ្មោះ [redacted] **សារឿន** (រ) ជាទីតិជន។

-លោកមេធាវី [redacted] លោកស្រី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គញ្ញាវី**។M



Scanned with CamScanner

## អង្គហេតុនៃរឿងមានដូចតទៅ:

-កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ [redacted] គឿន ភេទស្រី អាយុ៤៩ឆ្នាំ បានឱ្យកូនស្រីឈ្មោះ [redacted] MALIKA ហៅជនរងគ្រោះឈ្មោះ [redacted] កញ្ញារី ភេទស្រី អាយុ២៥ឆ្នាំ មកផ្ទះរបស់ជនជាប់ចោទដែលមានទីតាំងស្ថិតនៅផ្ទះលេខ៩៩ ផ្លូវលំ ភូមិត្រពាំងមាន សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពីដំណើររឿងទាក់ទងរបស់ប្តីឈ្មោះ [redacted] សារ៉េត។ នៅពេលដែលជនរងគ្រោះឈ្មោះ [redacted] កញ្ញារី បានមកផ្ទះរបស់ជនជាប់ចោទក៏បានជួបជនជាប់ចោទឈ្មោះ [redacted] គឿន និងបានសួរទៅកាន់ជនរងគ្រោះថា "មីឯងចុយគ្នាជាមួយប្តីអញប៉ុន្មានដង" ហើយជនជាប់ចោទឈ្មោះ [redacted] គឿន បានទាញកាំបិតប៉ុងតោមករកកាប់ជនរងគ្រោះ តែត្រូវកូនស្រីជួយទាញដៃចេញជាមួយគ្នានោះដែរឈ្មោះ នាងសារ៉េត បាននិយាយថា "គាត់លែងមានទំនាក់ទំនងជាមួយគ្នាជាង០១ឆ្នាំហើយ" ភ្លាមនោះឈ្មោះ [redacted] គឿន ខឹងខ្លាំងហើយងាកទៅរកចង់កាប់ប្តីវិញ បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] គឿន បានឱ្យជនរងគ្រោះអង្គុយបត់ជើងហើយក៏បានហក់មកធាក់លើជនរងគ្រោះចំដៃខាងស្តាំ រួចយកដៃចង្អុលក្បាលហើយហក់ធាក់ជនរងគ្រោះជាច្រើនលើកច្រើនសារបណ្តាលឱ្យរបួសជាំដៃទើបកូនស្រីរបស់ជនជាប់ចោទមកឃាត់។ ក្រោយមកទៀតជនជាប់ចោទឈ្មោះ [redacted] គឿន សួរជនរងគ្រោះថា "តើឯងបានលុយប៉ុន្មានពីប្តីអញ"? ដោយជនរងគ្រោះឆ្លើយថា "គាត់ឱ្យលុយ ១000$ មកជនរងគ្រោះតែលុយនោះគឺជាលុយដែលជនរងគ្រោះបានអះអាងថាឱ្យជួយរត់ការប្រលងចូលមន្ទីរពេទ្យគន្ធបុប្ផាទេ"។ ដោយការភ័យខ្លាចទើបជនរងគ្រោះបានបាញ់លុយឱ្យជនជាប់ចោទវិញទើបមួយសន្ទុះក្រោយមក កូនស្រីរបស់ជនជាប់ចោទឈ្មោះ [redacted] MALIKA ក៏បានបើកទ្វារផ្ទះឱ្យជនរងគ្រោះត្រឡប់មកផ្ទះវិញ។ ករណីនេះជនរងគ្រោះឈ្មោះ [redacted] កញ្ញារី ភេទស្រី អាយុ២៥ឆ្នាំ បានដាក់ពាក្យបណ្តឹងមកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-**បានឃើញ** ពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ របស់ដើមបណ្តឹងឈ្មោះ អ្នង កញ្ញារី។

-**បានឃើញ** ដីកាសន្និដ្ឋានស្ពាពរលេខ ៣៦៥១ អ.យ.ធ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ របស់តំណាងអយ្យការសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥០១៩ "ទ" ជ.ជ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **គឿន** បានឆ្លើយថា៖ ខ្លួនសុំបដិសេធថាខ្លួនមិនបានវាយដំទៅលើជនរងគ្រោះឈ្មោះ [redacted] កញ្ញារី ដូចការចោទប្រកាន់នោះទេ ដោយខ្លួនសូមបញ្ជាក់ថា នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ខ្លួនបានឱ្យកូនស្រីឈ្មោះ [redacted] ម៉ាលីកា ខលទៅហៅឈ្មោះ [redacted] កញ្ញារី ឱ្យមកជួបនៅផ្ទះរបស់ខ្លួនពីរឿងទំនាក់ទំនងលួចមានសាហាយជាមួយនឹងប្តីរបស់ខ្លួនមានទំនាក់ទំនងជាមួយគ្នា០៤ឆ្នាំមកហើយ។ ពេលឈ្មោះ [redacted] កញ្ញារី មកដល់ខ្លួនក៏បានសួរនាំដោយឈ្មោះ [redacted] កញ្ញារី បានជិះម៉ូតូចូលមកដល់ផ្ទះហើយកូនខ្លួនក៏បានទាញទ្វារបិទ តែមិនបានចាក់សោរនោះទេ។ ខ្លួនមិនបានឱ្យគេអង្គុយបត់ជើងនៅលើការ៉ូអ្វីទេ។ នៅពេលនោះឈ្មោះ [redacted] កញ្ញារី បានបដិសេធថាឈប់ទំនាក់ទំនងនឹងគ្នាយូរមកហើយ ចំណែកប្តីខ្លួនក៏បាននិយាយកុហក ខ្លួនថាពុំមានទំនាក់ទំនងនឹងគ្នាដែរ។ ពេលនោះខ្លួនបានចាប់ដើមដៃខាងស្តាំរបស់ឈ្មោះ [redacted] កញ្ញារី ហើយបានសួរថា "ប្តីរបស់ខ្លួនឱ្យលុយប៉ុន្មានទៅនាងឯង" ហើយឈ្មោះ [redacted] កញ្ញារី ក៏បានឆ្លើយតបថា "មិនដែលឱ្យលុយមកទេ គឺឱ្យតែ១000$ ដុល្លារអាមេរិក ប៉ុណ្ណោះ"។ ខ្លួនសុំបដិសេធថាខ្លួនមិនបានវាយដំទៅលើឈ្មោះ អ្នង កញ្ញារី ដូចការចោទប្រកាន់ថា បានហក់ធាក់និងវាយដំទៅលើឈ្មោះ [redacted] កញ្ញារី នៅពេលនោះឡើយ ខ្លួនសួរនាំតែពីរឿងលុយកាក់ដែលប្តីខ្លួនឱ្យប៉ុណ្ណោះ។ តាមដែលខ្លួនដឹងកន្លងមកគឺប្តីខ្លួនបានលួចលុយទៅទិញផ្ទះឱ្យឈ្មោះ [redacted] កញ្ញារី តែរឿងនេះខ្លួនមិនដឹងច្បាស់នោះទេ។ ចំពោះការចោទប្រកាន់ថាខ្លួនបាន

យកកាំបិតប៉ុងតោមករកកាប់ប្តីខ្លួននោះគឺខ្លួនបានចូលទៅផ្ទះបាយកាន់យកកាំបិត និងបានកាន់តែមួយភ្លែតបម្រុងដើរចេញមកក្រៅវិញស្រាប់តែចុងភៅឈ្មោះ គន្ធា បានដកយកពីដៃទៅវិញ។ ចំពោះប្តីខ្លួននៅពេលនោះពុំបានតបតអ្វីទាំងអស់ប្រសិនបើខ្លួនវាយដំទៅលើឈ្មោះ [redacted] កញ្ញារី មែននោះប្រហែលជាប្តីខ្លួនចូលឃាត់ហើយ តែប្តីខ្លួនមិនបានតបតអ្វីទេគ្រាន់តែអង្គុយមើលខ្លួនខឹងទៅលើស្រីគាត់ប៉ុណ្ណោះ។ ចំពោះរបួសស្នាមលើដៃនោះគឺប្រហែលនៅពេលខ្លួនចាប់ដៃនាងនោះសួរនៅក្នុងពេលនិយាយគ្នាតែឈ្មោះ[redacted] កញ្ញារី មិនព្រមឆ្លើយ។ នៅពេលនោះមិនបានស្រែកឡូឡានៅក្នុងផ្ទះឡើយ ដោយខ្លាចអ្នកជិតខាងបានឮ។ ក្រោយពេលសួរដឹងរឿងរ៉ាវទាំងអស់ហើយ ខ្លួនឱ្យឈ្មោះ[redacted]កញ្ញារី ត្រឡប់ទៅផ្ទះវិញ។ ចំពោះឈ្មោះ[redacted]កញ្ញារី ចោទប្រកាន់មកលើខ្លួនថាបានចាក់សោផ្ទះហើយវាយដំនោះគឺរឿងមិនពិតទេ ព្រោះមានប្តីនៅទីនោះក៏អាចដឹងឮ ពីរឿងទាំងអស់នេះដែរ។ ខ្លួនមិនជឿថាដៃរបស់ខ្លួនចាប់ដៃគាត់ជាំដល់ថ្នាក់នឹងទេ។ តាមខ្លួនដឹងឈ្មោះ[redacted] កញ្ញារី នេះ គឺមានជម្ងឺមហារីកគ្រាប់ឈាម ដោយប្តីខ្លួនធ្លាប់ឱ្យលុយទិញផ្ទះ និងធ្លាប់បញ្ចូលឈាមជាច្រើនលើក។

-ចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] **កញ្ញារី** បានឆ្លើយថា៖ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង៥ល្ងាចឈ្មោះ[redacted] គឿន បានគេហៅឱ្យខ្លួនទៅកាន់ផ្ទះរបស់គាត់ដោយឱ្យកូនស្រីឈ្មោះ [redacted] ម៉ាលីកា តេទូរស័ព្ទមកកាន់ខ្លួនតាមរយៈលេខ ០៩៦ ៣០៣ ៦៧៩២ និងបានផ្ញើ Location ទីតាំងផ្ទះមកកាន់ខ្លួន ក្នុងគោលបំណងដើម្បីនិយាយទំនាក់ទំនងស្នេហារវាងខ្លួន និងប្តីរបស់គាត់ឈ្មោះ[redacted] សារ៉េត។ នៅពេលទៅដល់ផ្ទះរបស់ឈ្មោះ [redacted] គឿន នៅម៉ោងប្រហែល ០៥ ជិត ០៦ ល្ងាចដោយខ្លួនបានទៅតែម្នាក់ឯង។ នៅផ្ទះរបស់ឈ្មោះ [redacted] គឿន ខ្លួនបានជួបជាមួយនឹងឈ្មោះ [redacted]សារ៉េត,កូនស្រីឈ្មោះ[redacted]ម៉ាលីកា និងកូនប្រុសឈ្មោះ[redacted] ឧត្តម ពេលចូលទៅដល់ក្នុងផ្ទះមានមនុស្សម្នាក់ចាក់សោរទ្វាររបងផ្ទះខាងក្រៅ។ ខ្លួនបានចូលទៅដល់កន្លែងបន្ទប់ទទួលភ្ញៀវ ដោយមានមនុស្សចំនួន ០៤នាក់រួមមានឈ្មោះ [redacted] គឿន បានសួរខ្លួនថា "ឯងចុយគ្នាជាមួយប្តីរបស់អញប៉ុន្មានដង" ខ្លួនមិនបានឆ្លើយតបនោះទេ ក្នុងពេលនោះខ្លួននៅឈរនៅឡើយទេ។ ឈ្មោះ [redacted] គឿន បានជេរប្រមាថមកលើខ្លួន ប៉ុន្តែខ្លួនមិនបានឆ្លើយតបនោះទេ ក្នុងពេលនោះខ្លួននៅឈរនៅឡើយទេ។ ឈ្មោះ [redacted]គឿន បានជេរប្រមាថមកលើខ្លួនថាខ្លួនយកប្តីគាត់ និងថាខ្លួនអាយុប៉ុណ្ណឹងធ្វើសំផឹង នៅពេលនោះខ្លួនប្រាប់ថា អត់ដឹងរឿងអ្វីទេឱ្យសួរប្តីរបស់គាត់ទៅ ពេលនោះឈ្មោះ [redacted] គឿន បានជេរប្រមាថមកកាន់ខ្លួនជាច្រើនទៀត ដែលខ្លួនចាំមិនអស់ទេ។ បន្ទាប់មកឈ្មោះ [redacted]គឿន បានយកកាំបិតប៉ុងតោមករកកាប់ខ្លួន តែត្រូវបានកូនស្រីឈ្មោះ [redacted]ម៉ានីកា ចូលមកឃាត់។ បន្ទាប់មកឈ្មោះ [redacted]គឿន បានយកកាំបិតប៉ុងតោមករកកាប់ខ្លួន តែត្រូវបានកូនស្រីឈ្មោះ[redacted] ម៉ានីកា ចូលមកឃាត់។ បន្ទាប់មកឈ្មោះ [redacted] គឿន បានឱ្យខ្លួនអង្គុយបត់ជើង ហើយបានធាក់ខ្លួនត្រូវចំដៃខាងស្តាំជាច្រើនជើងបណ្តាលឱ្យជាំដៃខាងស្តាំមួយកន្លែង និងបានបោចសក់ខ្លួន។ មួយសន្ទុះក្រោយមកប្រហែលម៉ោង៧ល្ងាច ទើបគេបើកទ្វារឱ្យខ្លួនចេញមកក្រៅវិញ។ ក្រោយមកខ្លួនបានត្រឡប់ទៅកាន់កន្លែងធ្វើការវិញ ប៉ុន្តែមិនបានទៅរកពេទ្យពិនិត្យនោះទេហើយក៏មិនបានដាក់ពាក្យប្តឹងទៅកាន់សមត្ថកិច្ចនោះដែរ។ មូលហេតុដែលខ្លួនទៅកាន់ផ្ទះរបស់ឈ្មោះ [redacted] គឿន ដោយសារតែគាត់ប្រាប់ថា បើមិនមកតាមទេ គាត់នឹងទៅអុកឡុកនៅកន្លែងធ្វើការរបស់ខ្លួន។ អំឡុងពេលដែលឈ្មោះ[redacted] គឿន ប្រើអំពើហិង្សាមកលើខ្លួន គឺមានវត្តមានប្តីរបស់គាត់ឈ្មោះ [redacted] សារ៉េត និងកូនស្រី កូនប្រុសនៅទីនោះ។ តែខ្លួនបានដាក់ពាក្យបណ្តឹងប្តឹងតែឈ្មោះ [redacted] គឿន ដែលជាអ្នកប្រើអំពើហិង្សាមកលើខ្លួនតែប៉ុណ្ណោះ ដោយសារពួកគាត់ទាំងនោះគ្រាន់តែឈរមើល និងបានជួយឃាត់ឈ្មោះ[redacted] គឿន កុំឱ្យប្រើអំពើហិង្សាទៀត។ នៅថ្ងៃបន្ទាប់ឈ្មោះ [redacted]គឿន បានគេមកគំរាមខ្លួនថា ប្រសិនបើថ្ងៃក្រោយមិនលើកលេខទូរស័ព្ទគាត់ គាត់នឹងទៅអុកឡុកខ្លួននៅកន្លែងធ្វើការ។ ខ្លួនទើបស្គាល់ឈ្មោះ [redacted] គឿន ដោយដឹងថាគាត់ជាប្រពន្ធរបស់ឈ្មោះ[redacted] សារ៉េត ដែលត្រូវគ្រូបង្រៀនរបស់ខ្លួន។ ហើយបានទៅផ្ទះរបស់ឈ្មោះ[redacted] គឿន បានចំនួន០១ដង កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២។ ចំពោះរូបថតជាំដៃខាងស្តាំដែលជាភស្តុតាងនោះ គឺមេធាវីខ្លួនបានថត នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ នៅពេលដែលខ្លួនបានទៅពឹងពាក់គាត់។ ខ្លួនសំណូមពរសុំឱ្យតុលាការផ្តន្ទា

ទោសឈ្មោះ [redacted] គឿន តាមផ្លូវច្បាប់ និងទាមទារសំណងជំងឺចិត្តនិងថ្លៃព្យាបាល របួសសរុបជាប្រាក់ចំនួន ៣០០.០០០ $ (សាមសិបម៉ឺន) ដុល្លារអាមេរិក។

-អំណានសាក្សីឈ្មោះ [redacted] ម៉ាលីកា បានឆ្លើយថា: ខ្លួនត្រូវជាកូនបង្កើតរបស់ឈ្មោះ [redacted] គឿន។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល៦ ល្ងាច ខ្លួនបានខលហៅឈ្មោះ [redacted] កញ្ញារី មកជួបនៅផ្ទះរបស់ខ្លួន។ ពេលនោះខ្លួនមិនបានចាក់សោអ្វីទេ គ្រាន់តែទាញទ្វាបិតធម្មតាប៉ុណ្ណោះ។ ខ្លួនគ្រាន់តែឱ្យគាត់អង្គុយលើកៅអី នៅក្នុងផ្ទះនោះទេ មិនបានឱ្យអង្គុយលើការ៉ូអ្វីឡើយ។ នៅពេលដែលឈ្មោះ [redacted] កញ្ញារី បានចូលមកដល់នោះខ្លួនបានឃើញដើមដៃខាងស្តាំរបស់គាត់មានស្នាមរបួសស្រាប់ហើយដោយហេតុថាពេលនោះគាត់បានដោះអាវដៃវែងហើយខ្លួនក៏បានមើលឃើញមួយភ្លែត។ ម្តាយខ្លួនមិនបានវាយដំហក់ផាក់ទៅលើឈ្មោះ [redacted] កញ្ញារី ទេពេលនោះគាត់គ្រាន់តែបានចាប់ទាញដើមដៃ ដើម្បីសួរនាំពីទំនាក់ទំនងរវាងប៉ាខ្លួន និងគាត់ប៉ុណ្ណោះ។ ម្តាយខ្លួនមានជម្ងឺឈឺជង្គង់ដូចនេះម្តាយខ្លួនម៉េចនឹងអាចហក់ផាក់ឈ្មោះ [redacted] កញ្ញារី បាន។ នៅពេលនោះម្តាយខ្លួនចូលទៅយកកាំបិតមកកាន់នឹងដៃមែនតែកាន់បានមួយភ្លែតស្រាប់តែត្រូវបានចុងភៅឈ្មោះ គន្ធា ហៅ ស្រី នាងយកទៅទុកវិញមិនបានយកទៅគំរាមកាប់ឈ្មោះ [redacted] កញ្ញារី អ្វីទេ។ គ្រាពេលនោះពួកខ្លួនបានសួរនាំគាត់ពីទំនាក់ទំនងរវាងប៉ាខ្លួន និងគាត់បានប្រហែល ១០នាទី ក៏ឱ្យគាត់ត្រឡប់ទៅវិញដោយខ្លួនជាអ្នកទៅបើកទ្វារឱ្យគាត់។

-អំណានសាក្សីឈ្មោះ [redacted] ឧត្តម បានឆ្លើយថា: ខ្លួនត្រូវជាកូនបង្កើតរបស់ឈ្មោះ [redacted] គឿន។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល៦ល្ងាច ខ្លួនក៏បាននៅទីនោះដែរ ដោយខ្លួនបានឃើញឈ្មោះ [redacted] កញ្ញារី បានជិះម៉ូតូចូលមកធម្មតា ដោយផ្ទះខ្លួនមិនបានចាក់សោរអ្វីទេ គឺប្អូនស្រីខ្លួនគ្រាន់តែបានទាញទ្វារបិទនោះទេ។ នៅពេលឈ្មោះ [redacted] កញ្ញារី ចូលមកដល់ក្នុងផ្ទះគាត់ក៏ទៅអង្គុយលើកៅអី បន្ទាប់មកពេលប៉ារបស់ខ្លួនមកដល់ ហើយម្តាយរបស់ខ្លួនបានសួរនាំពីទំនាក់ទំនងគាត់ និងប៉ាខ្លួនទៀតនោះ គាត់មានការភ័យ ហើយគាត់ក៏ទៅបត់ជើងនៅលើការ៉ូដោយខ្លួនឯង ដោយម្តាយរបស់ខ្លួនមិនបានឱ្យគាត់អង្គុយនៅលើការ៉ូអ្វីទេ។ ម្តាយខ្លួនមិនបានវាយដំហក់ផាក់ទៅលើឈ្មោះ [redacted] កញ្ញារី ទេពេលនោះ គាត់គ្រាន់តែបានចាប់ទាញដើមដៃ ដើម្បីសួរនាំពីទំនាក់ទំនងរវាងប៉ាខ្លួន និងគាត់ប៉ុណ្ណោះ។ ខ្លួនគ្រាន់តែអង្គុយស្តាប់ មិនបានថតវីឌីអូអ្វីទេ។ នៅពេលនោះម្តាយខ្លួនបានចូលទៅយកកាំបិត មកកាន់នឹងដៃមែន តែកាន់បានមួយភ្លែត ស្រាប់តែត្រូវបានចុងភៅឈ្មោះ គន្ធា ហៅ ស្រីនាង យកទៅទុកវិញ មិនបានយកទៅគំរាមកាប់ឈ្មោះ [redacted] កញ្ញារី អ្វីទេ។ ពេលនោះម្តាយខ្លួនបានសួរនាំគាត់ពីទំនាក់ទំនងរវាងប៉ាខ្លួននិងគាត់បានប្រហែល ១០នាទី ក៏ឱ្យគាត់ត្រឡប់ទៅវិញ ដោយប្អូនស្រីខ្លួនជាអ្នកទៅបើកទ្វារឱ្យ។

-អំណានសាក្សីឈ្មោះ [redacted] គន្ធា បានឆ្លើយថា: ខ្លួនត្រូវជាចុងភៅនៅផ្ទះរបស់ឈ្មោះ [redacted] គឿន។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល០៦ ល្ងាច ខ្លួនបានឃើញឈ្មោះ [redacted] កញ្ញារី ដើរចូលមកក្នុងផ្ទះហើយពេលគាត់ចូលមកហើយខ្លួនបានឃើញឈ្មោះ [redacted] ម៉ាលីកា ដើរទៅទាញទ្វារបិទតែមិនបានចាក់សោរអ្វីទេ។ ពេលនោះខ្លួនមិនបានឃើញអ្វីទេព្រោះខ្លួនកំពុងនៅផ្ទះបាយតែខ្លួនគ្រាន់តែបានដឹងថា ពេលនោះស្រាប់តែឈ្មោះ [redacted] គឿន ចូលមកផ្ទះបាយយកកាំបិត ខ្លួនក៏បានទាញពីដៃគាត់យកមកទុកវិញទៅ។ ខ្លួនមិនបានលឺឈ្មោះ [redacted] គឿន ស្រែកជេរ ឬមានសម្លេងវាយដំទៅលើឈ្មោះ [redacted] កញ្ញារី ទេ ហើយក៏មិនបានឮសម្លេងឈ្មោះ [redacted] កញ្ញារី ស្រែកយំអ្វីដែរ ព្រោះផ្ទះបាយ និងបន្ទប់ទទួលភ្ញៀវនោះ នៅមិនឆ្ងាយពីគ្នាប៉ុន្មានទេ។ ខ្លួនបានដឹងថាឈ្មោះ [redacted] កញ្ញារី បានមកផ្ទះនេះ មួយសន្ទុះ ក៏ត្រឡប់ទៅផ្ទះវិញ ដោយមានកូនស្រីរបស់ឈ្មោះ [redacted] គឿន ជាអ្នកជូនទៅក្រោយកម៉ូតូ។

-អំណានសាក្សីឈ្មោះ [redacted] សារ៉េត បានឆ្លើយថា: ខ្លួនត្រូវជាប្តីរបស់ឈ្មោះ [redacted] គឿន នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោងប្រហែល ០៦ល្ងាច ខ្លួនបាននៅទីនោះ។ កូនរបស់ខ្លួនឈ្មោះ [redacted] ម៉ាលីកា បានខលទៅហៅឈ្មោះ [redacted] កញ្ញារី ឱ្យមកផ្ទះរបស់ខ្លួនតាមការទាមទាររបស់ប្រពន្ធខ្លួនហើយពេលនោះប្រពន្ធខ្លួនមិនបានប្រាប់ទេ ហើយក៏បានចាប់ផ្តើម

សួរពីទំនាក់ទំនងរវាងខ្លួននិងឈ្មោះ [redacted] កញ្ញារី ចំពោះមុខកូនឈ្មោះ [redacted] ម៉ាលីកា និងកូនប្រុស០១ទៀតឈ្មោះ [redacted] ឧត្តម តែម្តង។ ប្រពន្ធខ្លួននៅពេលនោះមិនបានចាក់សោរទេ ដោយគ្រាន់តែឱ្យកូនស្រីទាញទ្វារបិទទេ ហើយក៏បានសួរនាំពីទំនាក់ទំនងរបស់ខ្លួននិងឈ្មោះ [redacted] កញ្ញារី។ ប្រពន្ធខ្លួនបានចាប់ដៃ ត្រង់ដើមដៃខាងស្តាំ សួរនាំពីទំនាក់ទំនងរវាងខ្លួនជាមួយឈ្មោះ [redacted] កញ្ញារី ថា "ទៅគេងជាមួយគ្នាប៉ុន្មានដងក្នុង ០១ខែ" ហើយ "ប្តីខ្ញុំឱ្យលុយទៅនាងឯងប៉ុន្មាន"។ ចំពោះការឱ្យអង្គុយនៅលើការ៉ូ សំពះ វាយដំ ហក់ធាក់ គឺមិនមែនទេ មានតែប្រពន្ធខ្លួនអង្វរខ្លួនឯងថា ឈប់ឱ្យទាក់ទងគ្នាទៀត។ ប្រពន្ធខ្លួនគ្រាន់តែយកកាំបិតពីផ្ទះបាយ បានបន្តិច ប៉ុន្តែក្រោយមកគឺខាងចុងភៅឈ្មោះ គន្ធា បានដកយកទៅវិញភ្លាមតែម្តង។ ពេលជួបគ្នាបានប្រហែល១០នាទីប៉ុណ្ណោះ។ ពេលចេញទៅផ្ទះវិញឈ្មោះ [redacted] កញ្ញារី ក៏បានទាញទ្វារបើក ហើយជិះម៉ូតូចេញទៅ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

ឆ្លងតាមការសាកសួរដេញដោលដើមបណ្តឹងពេលសវនាការស្តាប់អំណានចម្លើយសាក្សីនិងពិនិត្យឯកសារភស្តុតាងរួចមក ឃើញថាជនជាប់ចោទពិតជាបានធ្វើសកម្មភាពដោយប្រើកូនស្រីឱ្យទូរស័ព្ទហៅកូនក្តីខ្លួនមកជួបនៅផ្ទះរបស់ជនជាប់ចោទ។ ពេលកូនក្តីខ្លួនមកជួបជនជាប់ចោទ បានជេរប្រមាថបង្គាប់ឱ្យកូនក្តីខ្លួនលុតក្រាបសំពះ ហើយហក់ធាក់កូនក្តីខ្លួនរហូតមានស្នាមជាំនៅដើមដៃដូចមានក្នុងរូបថតដាក់បង្ហាញជូនតុលាការរួចហើយ និងសារឆ្លើយឆ្លងក្នុងឆាតរបស់សាក្សីឈ្មោះ [redacted] ម៉ាលីកា ដែលបង្ហាញពីការសោកស្តាយដែលម្តាយខ្លួនបានធ្វើមកលើជនរងគ្រោះនិងសារតាមតេឡេក្រាមរបស់ឈ្មោះ [redacted] សារ៉េត បានធ្វើសុំទោសជនរងគ្រោះផងដែរ។

ចំពោះចម្លើយដោះសាររបស់ជនជាប់ចោទដែលថាខ្លួនមិនបានហក់ធាក់ ជេរគំរាមជនរងគ្រោះមិនមែនជាការពិតទេ ពីព្រោះចម្លើយរបស់ជនជាប់ចោទឆ្លើយនៅដំណាក់កាលអយ្យការថាជនរងគ្រោះរត់ចុះឡើងនិងលុតជង្គង់លូនក្រាបសំពះខ្លួនបញ្ជាក់ឱ្យឃើញថាជនជាប់ចោទពិតជាបានគំរាមជនរងគ្រោះ ពិតមែន។

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ សុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឱ្យបានធ្ងន់ធ្ងរនឹងទាមទារសំណងជំងឺចិត្តចំនួន ៣០០០០$ (បីម៉ឺនដុល្លារអាមេរិក)។

## សេចក្តីសន្និដ្ឋានផ្លូវសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា ឆ្លងតាមការសាកសួរដេញដោលពេលសវនាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] គៀន ពិតជាបានប្រព្រឹត្តអំពើហិង្សាមកលើជនរងគ្រោះឈ្មោះ [redacted] កញ្ញារី ពិតមែនតាមចម្លើយសាក្សីដែលជាកូនៗរបស់ជនជាប់ចោទដែលឆ្លើយដោះសារថាជនជាប់ចោទមិនបានប្រព្រឹត្តអំពើហិង្សាលើជនរងគ្រោះ តែដោយផ្អែកលើឯកសារភស្តុតាងបញ្ជាក់ពីស្លាកស្នាមលើជនរងគ្រោះនិងសារសន្ទនាផ្សេងៗបញ្ជាក់ឃើញថាជនជាប់ចោទឈ្មោះ [redacted] គៀន ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ សុំរក្សាបទចោទនឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

តាមចម្លើយកូនក្តីនៅតំណាក់អយ្យការនិងចៅក្រមស៊ើបសួរគាត់បានឆ្លើយថា មិនបានប្រព្រឹត្តហក់ធាក់ជនរងគ្រោះទេ ម្យ៉ាងកូនក្តីខ្លួនមានអាយុច្រើនមានជំងឺឈឺជង្គង់មិនអាចហក់ធាក់ជនរងគ្រោះជាច្រើនជើងត្រូវកន្លែងដដែលៗបានទេ។ ម្យ៉ាងតាមសាក្សី [redacted] សារ៉េត ថាជនរងគ្រោះធ្លាប់មានជម្ងឺគ្រាប់ឈាមផងដែល ប្រសិនបើរបួសស្នាមកើតឡើងនៅពេលកើតហេតុ ចុះក្រោយពេលកើតហេតុម្តេចជនរងគ្រោះមិនទៅព្យាបាលគ្មានលិខិតបញ្ជាក់ពីការព្យាបាលរបួសស្នាម កូនក្តីខ្លួនជាមនុស្សមានការអត់ទ្រាំខ្ពស់ បើគាត់ជាមនុស្សចង់ប្រើកម្លាំងបាយ មិនមែនឱ្យកូនទូរស័ព្ទហៅដើមបណ្តឹងមកជជែកគ្នាដល់ផ្ទះទេ។ ចំពោះការប្រើសំដីអសុរសប្រហែលមានមែនដោយសារកូនក្តីខ្លួនមានការឈឺចាប់ ⅃⅃



Scanned with CamScanner

ខ្លាំង។ ចំពោះរូបថតបង្ហាញពីស្លាក់ស្នាមរបួសដែលដើមបណ្តឹងបានបង្ហាញអាចជាការច្នៃប្រឌិតរហូតមកដល់ពេលនេះ ដើមបណ្តឹងគ្មានសំបុត្រពេទ្យបញ្ជាក់ទេ សុំឱ្យតុលាការពិចារណាពីវិមតិសង្ស័យដែលគ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើកូនក្តីខ្លួនទេ។

**តុលាការ**

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១.តុលាការបានទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ៧៧៩ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលតុលាការមានសមត្ថកិច្ចជំនុំជម្រះ ស្របតាមមាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ នៅផ្ទះលេខ:៩៩ ភូមិត្រពាំងមាន សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានអំពើហិង្សាដោយចេតនា ដែលប្រព្រឹត្តដោយឈ្មោះ [redacted] គឿន ភេទស្រី អាយុ៤៩ឆ្នាំ ទៅលើជនរងគ្រោះឈ្មោះ [redacted] កញ្ញារី ភេទស្រី ពិតមែន។

៣.បុគ្គលដែលត្រូវបានបញ្ជូនមកចំពោះមុខតុលាការ ជាជនជាប់ចោទមានឈ្មោះ [redacted] **គឿន** ភេទស្រី អាយុ៤៩ឆ្នាំ ជាប់ចោទពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅផ្ទះលេខ៩៩ ផ្លូវលំ ភូមិត្រពាំងមាន សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

៤.តាមអំណានចំលើយជនជាប់ចោទឈ្មោះ [redacted] **គឿន** បានឆ្លើយដោះសារថា: ខ្លួនមិនបានវាយជនរងគ្រោះឈ្មោះ [redacted] កញ្ញារី នោះទេ។ ការឆ្លើយដោះសាររបស់ជនជាប់ចោទ ពុំមានភស្តុតាងត្រឹមត្រូវតាមរយៈភស្តុតាងមានដូចជា: រូបថតស្នាមជាំដៃរបស់ជនរងគ្រោះឈ្មោះ [redacted] កញ្ញារី។ សារជាអក្សររបស់កូនជនជាប់ចោទផ្ញើរឱ្យជនរងគ្រោះ [redacted] កញ្ញារី "នេះហើយជាមេរៀនហើយក៏សុំទោសសម្រាប់ទង្វើរបស់ម៉ាក់ ព្រោះគាត់ឈឺចាប់ខ្លាំងណាស់ ទោះយ៉ាងណាញូមនៅចាំការពារ បើប៉ាញូមមិចទៀតចាំទាក់ទងមកញូមមកការពារខ្លួនឱ្យ"។ សារជាអក្សរដែលប្តីជនជាប់ចោទផ្ញើរឆ្លងឆ្លើយជាមួយជនរងគ្រោះដូចជាជនរងគ្រោះថា "មានដែលយល់សប្តិឃើញអ្នកផ្ទះវាយធ្វើបាបខ្ញុំទេ" ហើយប្តីរបស់ជនជាប់ចោទបានតបថា "ឃើញហើយឈឺចាប់ដែលមិនអាចជួយបាន"។ ចំណុចទាំងអស់នេះ ជាភស្តុតាងប្រយោលអាចបង្ហាញឱ្យឃើញបាននូវភស្តុតាងផ្ទាល់ ដែលបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] គឿន ពិតជាបានវាយទៅលើជនរងគ្រោះឈ្មោះ [redacted] កញ្ញារី កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ដូចការចោទប្រកាន់មែន។ M



Scanned with CamScanner

៥.តាមការឆ្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] កញ្ញារី នាពេលសវនាការ និងចំលើយនៅក្នុងកំណត់ហេតុសួរចំលើយរបស់តំណាងអយ្យការនិងចៅក្រមស៊ើបសួរ អាចឱ្យតុលាការជឿបានថាជនរងគ្រោះ ពិតជាបានទទួលរងនូវអំពើហិង្សាដែលជនជាប់ចោទឈ្មោះ [redacted] គឿន បានប្រព្រឹត្តមកលើខ្លួន ដោយស្របទៅនឹងភស្តុតាងប្រយោលផ្សេងៗដូចជាសំណេរបស់ឈ្មោះ [redacted] ម៉ាលីកា និងសំណេររបស់ឈ្មោះ [redacted] សារ៉េត ដែលបានសរសេរផ្ញើរទៅជនរងគ្រោះ។

៦.តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ម៉ាលីកា,ឈ្មោះ [redacted] ឧត្តម,ឈ្មោះ [redacted] គន្ធា និងឈ្មោះ [redacted] សារ៉េត ដែលត្រូវជាកូនបង្កើត ជាចុងភៅ និងជាប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] គឿន បានឆ្លើយប្រហាក់ប្រហែលគ្នាថា "ចំពោះការឱ្យជនរងគ្រោះឈ្មោះ [redacted] កញ្ញារី អង្គុយលើការ៉ូ ហើយជនជាប់ចោទឱ្យជនរងគ្រោះសំពះ ជនជាប់ចោទបានវាយធំ ហក់ធាក់ គឺមិនមានទេ" ជនជាប់ចោទបានអង្វរជនរងគ្រោះ កុំឱ្យទាក់ទងជាមួយប្តីខ្លួន។ ចំលើយសាក្សីទាំងអស់មិនអាចឱ្យជឿបានឡើយពីព្រោះសាក្សីជាកូន,ជាប្តីនិងជាចុងភៅរបស់ជនជាប់ចោទ មិនឆ្លើយដាក់បន្ទុកលើជនជាប់ចោទនោះទេ។ ជាពិសេសចំលើយសាក្សីឈ្មោះ [redacted] សារ៉េត ផ្ទុយពីសំណេរដែលខ្លួនផ្ញើទៅជនរងគ្រោះថា "ឃើញហើយឈឺចាប់ដែលមិនអាចជួយបាន" សំណេរនេះបញ្ជាក់បានថា សាក្សីឈ្មោះ [redacted] សារ៉េត បានឃើញប្រពន្ធរបស់ខ្លួនវាយជនរងគ្រោះពិតប្រាកដ។ ចំពោះសាក្សីឈ្មោះ [redacted] ម៉ាលីកា ដែលសរសេរផ្ញើរទៅជនរងគ្រោះថា "នេះហើយជាមេរៀនហើយក៏សុំទោសសម្រាប់ទង្វើរបស់ម៉ាក់ព្រោះគាត់ឈឺចាប់ខ្លាំងណាស់ទោះជាយ៉ាងណា ញុម (ខ្ញុំ) នៅចាំការពារ បើប៉ាញុម (ខ្ញុំ) មិចទៀតចាំទាក់ទងមកខ្ញុំមក ខ្ញុំការពារខ្លួនឱ្យ"។ សំណេរសាក្សីនេះមានន័យថា សាក្សីបានឃើញម្តាយខ្លួនជាជនជាប់ចោទ បានប្រើហិង្សាទៅលើជនរងគ្រោះពិតប្រាកដ។

៧.សេចក្តីសន្និដ្ឋានរបស់លោកមេធាវីឈ្មោះ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណី មានលក្ខណៈត្រឹមត្រូវសមហេតុផល តុលាការទទួលយកមកពិចារណាបាន។

៨.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការថា: រក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] គឿន និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ពីព្រោះមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជនជាប់ចោទពិតជាបានប្រើហិង្សាលើជនរងគ្រោះពិតមែន។ ការសន្និដ្ឋានរបស់តំណាងអយ្យការត្រឹមត្រូវតុលាការទទួលយកនិងសម្រេចតាមការប្តឹងសុំ។

៩.សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ ថាជនជាប់ចោទមិនបាប្រព្រឹត្តហិង្សាទៅលើជនរងគ្រោះនោះទេ ដោយហេតុថាជនជាប់ចោទមានវ័យចាស់ មានជំងឺឈឺជង្គង់មិនអាចវាយជនរងគ្រោះកើតនោះឡើយ។ ការសន្និដ្ឋានរបស់លោកមេធាវី គ្មានភស្តុតាងត្រឹមត្រូវដែលបញ្ជាក់ថាជនជាប់ចោទមិនបានវាយជនរងគ្រោះនោះទេ។ ហេតុនេះការសន្និដ្ឋានការពារជនជាប់ចោទ តុលាការពុំទទួលយកមកពិចារណាទេ។

១០.ជនជាប់ចោទឈ្មោះ [redacted] គឿន ជានីតិជន មាននីតិសម្បទាគ្រប់គ្រាន់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជនជាប់ចោទជាមនុស្សដែលយល់ដឹងបាននូវបច្ច័យដែលកើតឡើងពីអំពើរបស់ខ្លួន តែជនជាប់ចោទនៅតែប្រព្រឹត្តដោយចេតនា ដោយសាការប្រច័ណ្ឌប្តីរបស់ខ្លួនជាមួយជនរងគ្រោះ។

១១.អំពើរបស់ជនជាប់ចោទ បានបណ្តាលឱ្យមានរបួសលើរូបកាយជនរងគ្រោះជាបទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

១២.មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] គឿន ភេទស្រី អាយុ៥៩ឆ្នាំ (អត្តសញ្ញាណដូចខាងលើ)។

ពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅផ្ទះលេខ៩៩ ផ្លូវលំ ភូមិត្រពាំងមាន សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ ស្របតាមមាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

១៣.ជនជាប់ចោទឈ្មោះ [redacted] គឿន ជាស្ត្រីមានវ័យចាស់អាយុ៤៩ឆ្នាំ។ ជនជាប់ចោទ ត្រូវបានជាប់ចោទពីបទមជ្ឈិម ដែលពុំទាន់មានការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារជាស្ថាពរមុនអំពើល្មើសដែលចោទប្រកាន់នេះទេ រីឯទោសដែលនឹងត្រូវប្រកាសតិចជាង០៥ឆ្នាំ តាមមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ អាចប្រកាសទោសព្យួរធម្មតាបាន គប្បីតុលាការឱ្យជនជាប់ចោទអនុវត្តទោសព្យួរធម្មតា។

១៤.ជនរងគ្រោះឈ្មោះ [redacted] កញ្ញារី បានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងចំពោះមុខសវនាការត្រឹមត្រូវតាមច្បាប់។ ដើមបណ្ដឹងរដ្ឋប្បវេណី សុំទាមទារសំណងព្យាបាលនិងជំងឺចិត្តសរុប ៣០០០០$ (បីម៉ឺនដុល្លារអាមេរិក) តែដើមបណ្ដឹងគ្មានភស្តុតាងបង្ហាញឱ្យឃើញពីការចំណាយព្យាបាលនោះទេ គប្បីតុលាការពិចារណាសម្រេចតាមការជាក់ស្តែង។ ដោយផ្អែកតាមការពិនិត្យមើលរូបថតជាភស្តុតាងឃើញមានស្នាមជាំដៅនៅត្រង់ដៃនោះមិនត្រូវព្យាបាលដោយចំណាយប្រាក់ច្រើននោះទេ។

១៥.ជនជាប់ចោទឈ្មោះ [redacted] គឿន បានកោះឱ្យចូលសវនាការ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង០២រសៀល ត្រឹមត្រូវតាមច្បាប់ តែគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាម៉ីខ្លួនបានដឹងពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ តាមមាត្រា៣៦២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះសម្រេច</u>

១.ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **គឿន** ភេទស្រី អាយុ៤៩ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ០១ (មួយ)ឆ្នាំ ០៦(ប្រាំមួយ)ខែ តែឱ្យអនុវត្តទោសព្យួរធម្មតា។

ពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅផ្ទះលេខ៩៩ ផ្លូវលំ ភូមិត្រពាំងមាន សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្ដន្ទាទោសតាមមាត្រា២១៧ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឱ្យឈ្មោះ [redacted] **គឿន** បង់សំណងព្យាបាលរបួសនិងជំងឺចិត្តសរុបចំនួន ៦ ០០០ ០០០រៀល (ប្រាំមួយលានរៀល) ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] កញ្ញារី ការប្ដឹងសុំលើសពីនេះច្រានចោល។

៣.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទនិងចំពោះមុខភាគីដើមបណ្ដឹងរដ្ឋប្បវេណី និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ចំពោះមុខភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទ។

ទុកសិទ្ធិឱ្យប្ដឹងទាស់និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និង ត្រា ៖ [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និង ត្រា [redacted]

**បានឃើញ**
**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]